ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៩២៣
ចុះថ្ងៃទី ២២.១០.០៧
សាលដីកា
លេខ :២៣"ញ"
ចុះថ្ងៃទី ២៣.៣.១០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ :០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០ ដោយមានសមាសភាពចូលរួមដូចតទៅ :

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជីសវនាការ

អ្នកស្រី [redacted]

*ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌចោទលេខ :៩២៣ ចុះថ្ងៃទី ២២ ខែ ១០ ឆ្នាំ ២០០៧ ដែលមាន :*

១. ជនជាប់ចោទឈ្មោះ [redacted] កុសល ហៅ ម៉ៅ ភេទប្រុស ជាតិខ្មែរ អាយុ ២១ឆ្នាំ របររកស៊ី មិនពិតប្រាកដ មានទីលំនៅសព្វថ្ងៃមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "វ" នៅលីវ ។ (ឃុំខ្លួនថ្ងៃទី ១១-៧-២០០៥)

២. ជនជាប់ចោទឈ្មោះ [redacted] សារីន ភេទប្រុស ជាតិខ្មែរ អាយុ ១៩ឆ្នាំ របររកស៊ី សិស្ស មានទីលំនៅសព្វថ្ងៃផ្ទះលេខ: [redacted] ក្រុង [redacted] ។(ឃុំខ្លួនថ្ងៃទី ០៥-៨-២០០៥)

__ត្រូវចោទពីបទ__ :ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅក្រុង ភ្នំពេញ កាលពីថ្ងៃទី ២៦ ខែ ៦ ឆ្នាំ ២០០៥ ។

*បទល្មើសដែលមានចែង និង ឲ្យផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។*

-មានលោកមេធាវី [redacted] ចន្ថា ជាមេធាវីការពារ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ អាយុ ២៥ឆ្នាំ មុខរបរ បុគ្គលិកក្រុមហ៊ុន មានទីលំនៅសព្វថ្ងៃផ្ទះលេខ: [redacted]

១៨២





Scanned with CamScanner

[redacted]។

- មានលោកស្រី [redacted] ធនលាភី ជាមេធាវីតំណាង

តាមសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ :៥៥២ ចុះថ្ងៃទី ០៥ ខែ ១០ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] សារីន និង សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ :៣៧៨ ចុះថ្ងៃទី ២៣ ខែ ៨ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] កុសល ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ : ៩៨(ឃ) ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៧ របស់សាលាដំបូងរាជធានី ភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល និង ចំណុចទី២ នៃសេចក្ដីសម្រេចសាលក្រម ។

*ឯរឿងហេតុមានដូចតទៅ*:

កាលពីថ្ងៃទី ២៦ ខែ ៦ ឆ្នាំ ២០០៥ នៅសង្កាត់ បឹងកក់២ ខណ្ឌ ទួកគោក ជនរងគ្រោះបានជិះម៉ូតូសេ ១២៥ ពណ៌ខ្មៅ ចេញពីកន្លែងទិញថ្នាំពេទ្យនៅផ្សារមាន់អាំងក្នុងគោលបំណងទៅផ្ទះ ។ ស្រាប់តែមានជនល្មើសពីរនាក់ជិះម៉ូតូសេ១២៥ ស៊េរី ២០០៥ មកកៀរម៉ូតូជនរងគ្រោះឲ្យឈប់ តែជនរងគ្រោះបំរុងគេច ស្រាប់តែមានជនល្មើស០២នាក់ទៀតជិះម៉ូតូម៉ាកស្មាស់ពណ៌ខ្មៅ ស៊េរី ២០០៥ មកឈប់ពីក្រោយហើយជនល្មើសម្នាក់បានដកអាវុធខ្លីម៉ាកកា៥៩ ភ្ជង់ទៅលើជនរងគ្រោះហើយប្លន់យកម៉ូតូជិះចេញទៅ ភ្លាមនោះជនរងគ្រោះបានស្រែកឲ្យគេជួយហើយសមត្ថកិច្ចដែលឈរជើងនៅគោលដៅបានបាញ់ធ្វើអន្តរាគមន៍ធ្វើឲ្យជនល្មើសភ័យស្លន់ស្លោរបានផ្តួលម៉ូតូរបស់ជនរងគ្រោះចោល រួចរត់ឡើងជិះម៉ូតូម៉ាកស្មាសរបស់បក្ខពួកវាជិះគេចខ្លួនបាត់ទៅ ។

បានឃើញចម្លើយរបស់ឈ្មោះ [redacted] សំណាង ជាជនរងគ្រោះឆ្លើយថា កាលពីថ្ងៃទី ២៦ ខែ ៦ ឆ្នាំ ២០០៥ វេលាម៉ោង១០:៤៥នាទី ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកសេ ១២៥ បិទតែម ២០០៥ ពណ៌ខ្មៅមកទិញថ្នាំពេទ្យនៅចំណុចផ្លូវកែង ៥៩២ កែងផ្លូវ៣១៣ ក្នុងសង្កាត់ បឹងកក់២ មុខផ្ទះលេខ:១០១ ស្រាប់តែមានជនល្មើសពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ មកកៀរម៉ូតូខ្លួនឲ្យដួល ខ្លួនលើកម៉ូតូបំរុងគេចខ្លួន ស្រាប់តែមានជនល្មើសពីរនាក់ទៀតជិះម៉ូតូមួយគ្រឿងម៉ាកស្មាស់មកឃាំងពីមុខខ្លួន ហើយជនល្មើសម្នាក់មកភ្ជង់លើរូបខ្លួន ដោយភ័យពេកខ្លួនក៏រត់ចោលម៉ូតូហើយជនល្មើសក៏លើកម៉ូតូខ្លួនជិះចេញទៅតាមផ្លូវ៥៩៨ដោយមានគ្នាវាជិះបិទគូថតាមក្រោយ។ ពេលក្រុមចោរជិះម៉ូតូបាន២០ម ខ្លួនស្រែកថា ចោរ ៗ ពេលនោះមាននគរបាលម្នាក់ស្លៀកពាក់ស៊ីវិលកំពុកកាត់សក់នៅកាច់ជ្រុងផ្លូវនោះគាត់ក៏បាញ់សំដៅទៅលើជនល្មើស ៗ បាញ់តវិញ ជនល្មើសដែលជិះម៉ូតូខ្លួនក៏ដួលម៉ូតូហើយរត់ឡើងម៉ូតូគ្នាវាជិះគេចខ្លួនបាត់ទៅ ។ ចំពោះម៉ូតូដែលចោរប្លន់នោះខ្លួនទទួលវិញហើយ រីឯជនល្មើសផ្តន្ទាទោសតាមច្បាប់ ។

បានឃើញចម្លើយរបស់ឈ្មោះ [redacted] សារីន ជាជនជាប់ចោទឆ្លើយថា ខ្លួននៅតែសុំបដិសេធចំពោះការចោទប្រកាន់លេខ: ២៨០១ ចុះថ្ងៃទី ០៨-៧-២០០៥ របស់ព្រះរាជអាជ្ញាអមតុលាការក្រុង ភ្នំពេញដដែល ។ កាលពីថ្ងៃទី ២៦-៦-២០០៥ ខ្លួនពុំ បានចូលរួមប្លន់ម៉ូតូគេទេ ព្រោះពេលនោះខ្លួននៅជាមួយឈ្មោះ [redacted] ឡេងហាំង នៅសាលារៀនសន្ធរម៉ុក នៅថ្ងៃនោះខ្លួនក៏បានឃើញឈ្មោះ [redacted] កុសល ជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅជិះម៉ូតូនោះឌុបឈ្មោះ [redacted] សុខៃ ហើយខ្លួនស្រែកហៅពួកគេដែរ តែគាត់ពុំឈប់ហើយពួកខ្លួនបានជិះម៉ូតូតាមពីក្រោយតែជិះតាមពុំទាន់ក៏ពួកខ្លួនជិះត្រឡប់មកសាលារៀនសន្ធរម៉ុកវិញ ។

បានឃើញចម្លើយរបស់ឈ្មោះ [redacted] កុសល ជាជនជាប់ចោទឆ្លើយថា នៅថ្ងៃទី ២៦-៦-២០០៥ ខ្លួនពិតជាបានធ្វើសកម្មភាពប្លន់យកម៉ូតូគេពិតមែន តែពុំបានសម្រេចដោយប៉ូលីស/

ឃើញហើយបានបាញ់មកលើពួកខ្លួន ។ ពេលប្លន់នោះមានគ្នាពីនាក់ខ្លួន([redacted] កុសល) និង ឈ្មោះ [redacted] សុខៃ ដោយជិះម៉ូតូសេ១២៥ ពណ៌ខ្មៅ ខ្លួនជាអ្នកឌុប ឈ្មោះ [redacted] សុខៃ អង្គុយពីក្រោយ ដោយហានកាំភ្លើងខ្លីមួយដើមផង ហើយឈ្មោះ [redacted] ឡេងហាំង និង ឈ្មោះ [redacted] សារីន ពួកវាពុំបានចូលរួមប្លន់ម៉ូតូជាមួយខ្លួនទេនៅក្នុងថ្ងៃកើតហេតុនោះ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ :៩៨(ឍ) ចុះថ្ងៃទី ០៨ ខែ ៨ ឆ្នាំ ២០០៧ របស់សាលាដំបូងរាជធានី ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១. លើកលែងចោទប្រកាន់លើឈ្មោះ [redacted] សុឃុនឡៃ ភេទស្រី អាយុ ១៨ឆ្នាំ ជាតិខ្មែរ ពីបទ:ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅក្រុង ភ្នំពេញ កាលពីថ្ងៃទី ២៦-៦-២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

២. ផ្តន្ទាទោស:

-លើឈ្មោះ [redacted] សុខៃ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ

-លើឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ

-លើឈ្មោះ [redacted] សារីន ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ ៗ កំណត់រយ:ពេល៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១១-៧-២០០៥ សម្រាប់ឈ្មោះ ជួន សុខៃ និង ចាន់ កុសល ឃុំខ្លួនថ្ងៃទី ០៥-៨-២០០៥ សម្រាប់ឈ្មោះ [redacted] សារីន ពីបទ:ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅក្រុង ភ្នំពេញ កាលពីថ្ងៃទី ២៦-៦-២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

៣. កែប្រែអាយុរបស់ឈ្មោះ [redacted] ឡេងហាំង ភេតប្រុស អាយុ ២២ឆ្នាំ មកអាយុពិតប្រាកដ១៦ឆ្នាំវិញ តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតចុះថ្ងៃទី ១៦-៨-២០០៥ ដែលចុះហត្ថលេខាដោយលោក ម៉ែន សិរី ជាអភិបាលរងខណ្ឌ ទួលគោក ក្រុងភ្នំពេញ ។

៤. ផ្តន្ទាទោសលើឈ្មោះ [redacted] ឡេងហាំង ភេតប្រុស អាយុ ១៦ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ ៗ កំណត់រយ:ពេល០៣ឆ្នាំ (បីឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១១-៧-២០០៥ ពីបទ:ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅក្រុង ភ្នំពេញ កាលពីថ្ងៃទី ២៦-៦-២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ និង យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ ។

៥. ផ្តន្ទាទោស:

-លើឈ្មោះ [redacted] សុខៃ ភេទប្រសុ អាយុ ២៥ឆ្នាំ ជាតិខ្មែរ

-លើឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ

-លើឈ្មោះ [redacted] សារីន ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ ៗ កំណត់រយ:ពេល៦ខែ (ប្រាំមួយខែ) និង ពិន័យជាប្រាក់៥០ម៉ឺនរៀលក្នុងម្នាក់ ៗ ដើម្បីដាក់ចូលថវិការដ្ឋនៅពេលសាលក្រមស្ថាពរ គិតពីថ្ងៃចាប់ខ្លួនបានសម្រាប់ឈ្មោះ [redacted] ប្រុស និង គិតបន្តពីថ្ងៃអនុវត្តទោសមុនចប់សម្រាប់ឈ្មោះ [redacted] សុខៃ ពីបទប្រើប្រាស់អាវុធខុសច្បាប់ និង ផ្ទេរអាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុង ភ្នំពេញ កាលពីថ្ងៃទី ២៦-៦-២០០៥ តាមមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងជាតិផ្ទុះ និង គ្រាប់រំសេវ ។

៦. វត្ថុតាង

អាវុធខ្លីធុនកា ៥៩ ចំនួន០១ដើមលេខគូ ៣០៥៧ និង បង់ចំនួនមួយត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋនៅពេលសាលក្រមស្ថាពរ ។



Scanned with CamScanner

-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] សុខៃ , [redacted] កុសល , [redacted] សារីន [redacted] ឡេងហាំង និង [redacted] សុយុនឡៃ មេធាវីជនជាប់ចោទ តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប្រុស និង ជនរងគ្រោះ សម្រេចទុកសិទ្ធិប្តឹងទាស់-និង-ឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ២៩ ខែ ៦ ឆ្នាំ ២០០៩ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី ១៨ ខែ ១១ ឆ្នាំ ២០០៨ របស់សាលាឧទ្ធរណ៍ ។

បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជំរះលេខៈ ៩៨៩/០៩ចុះថ្ងៃទី ២៩ ខែ ៩ ឆ្នាំ ២០០៩ របស់សាលាឧទ្ធរណ៍ ។

បានឃើញដីកាចាត់តាំងមេធាវីលេខៈ ៨៧ រប.ឧ១០ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០ របស់ប្រធានក្រុមប្រឹក្សាជំនុំជំរះ ។

## នាពេលសវនាការ

ដើមបណ្តឹងឈ្មោះ [redacted](អវត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] សារីន (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

តំណាងមហាអយ្យការសន្និដ្ឋានថា ដោយជនជាប់ចោទបានសារភាពទទួលកំហុសរបស់ខ្លួនបានប្រព្រឹត្តនោះឃើញថា ចម្លើយសារភាពរបស់ជនជាប់ចោទជាភស្តុតាងដាក់បន្ទុករួចហើយ ឯសាលក្រមដែលបានសម្រេចរួចមកនេះបានផ្តន្ទាទោសជនជាប់ចោទ៥ឆ្នាំធនល្មមនឹងកំហុស គួរតម្កល់សាលក្រមនេះទុកជាបានការដដែល ។

លោក [redacted] ចន្ថា សន្និដ្ឋានការពារថា ដោយកូនក្តីខ្លួនបានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តប្លន់កាលពីថ្ងៃទី ២៦-៦-២០០៧ ពីជនរងគ្រោះប្រាកដមែន ឯម៉ូតូរបស់ជនរងគ្រោះបានទទួលយកវិញហើយៗដោយមានចម្លើយសារភាព សូមក្រុមប្រឹក្សាបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួនផង

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារឲ្យរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យឯកសារដែលពាក់ព័ន្ធក្នុងសមណុំរឿង

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## <u>សាលាឧទ្ធរណ៍-យល់ឃើញថា</u>

១.ក- បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៣ ខែ ៨ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] កុសល ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ខ- បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥ ខែ ១០ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] សារីន ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] កុសល នៅសមត្ថកិច្ចក៏ដូចជានៅតុលាការបានសារភាពថា កាលពីថ្ងៃទី ២៦-៦-២០០៥ ពួកខ្លួនពិតជាបានធ្វើសកម្មភាពប្លន់យកម៉ូតូពិតប្រាកដមែន ប៉ុន្តែពុំបានសម្រេចដោយប៉ូលីសបាញ់ប្រហារមកលើពួកខ្លួន ។ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] សារីន បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្ត តែថា នៅថ្ងៃកើតហេតុខ្លួនបានឃើញជនជាប់ចោទឈ្មោះ [redacted] សារីន និង ឈ្មោះ [redacted] សុខៃ ហើយខ្លួនជិះម៉ូតូតាម ដូចច្នេះឃើញថាជនជាប់ចោទឈ្មោះ [redacted] សារីន ជាសហចារីក្នុងការប្រព្រឹត្តបទល្មើសដែរ ។

៣. តាមការបញ្ជាក់របស់ជនរងគ្រោះឈ្មោះ [redacted] សំណាង ថា កាលពីថ្ងៃទី ២៦-៦-២០០៧ វេលាម៉ោង ១០:៤០នាទី ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ មកពីទិញថ្នាំ ស្រាប់តែជនល្មើសពីរនាក់ជិះម៉ូតូមួយគ្រឿងមកកៀរម៉ូតូរបស់ខ្លួនបណ្តាលឲ្យដួល ខ្លួនលើកម៉ូតូបំរុងគេចស្រាប់តែមានជនល្មើសពីរនាក់ទៀតជិះម៉ូតូមកស្ទាក់ពីមុខម៉ូតូខ្លួនហើយដកកាំភ្លើងខ្លីភ្ជង់ខ្លួន ។ ភ័យក៏ទុកម៉ូតូចោលរត់គេចខ្លួន ចំណែកឯជនល្មើសបានយកម៉ូតូខ្លួនជិះបានប្រហែល២០ម៉ែត្រខ្លួនស្រែកថា ចោរ ។ មាននគរបាលម្នាក់កំពុងកាត់សក់បានបាញ់ទៅលើជនជាប់ចោទ ហើយជនជាប់ចោទបានបាញ់តប ។ ចំពោះជនល្មើសដែលជិះម៉ូតូខ្លួនបានផ្តួលម៉ូតូចោលហើយទៅជិះម៉ូតូគ្នាវាគេចខ្លួនបាត់ទៅ ។

៤. ជនជាប់ចោទចាប់ខ្លួនបានក្នុងករណីជាក់ស្តែង

៥. តាមការយល់ឃើញខាងលើបញ្ជាក់ថា ពិតជាមានភស្តុតាង និង ពិរុទ្ធភាពលើឈ្មោះ [redacted] កុសល និង ឈ្មោះ [redacted] សារីន ពីបទៈប្លន់ ប្រព្រឹត្តនៅក្រុង ភ្នំពេញ កាលពីថ្ងៃទី ២៦-៦-២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៦. សាលក្រមព្រហ្មទណ្ឌលេខៈ ៩៨(ឈ) ចុះថ្ងៃទី ០៨ ខែ ៨ ឆ្នាំ ២០០៧ របស់សាលាដំបូងរាជធានី ភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការពេញទាំងមូល ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១. ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៣ ខែ ៨ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៥-១០-២០០៧ របស់ឈ្មោះ [redacted] សារីន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ : ៩៨(ឈ) ចុះថ្ងៃទី ០៨-៨-២០០៧ របស់សាលាដំបូងរាជធានី ភ្នំពេញ ទុកជាបានការដដែល ។

៣. បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] កុសល និង ឈ្មោះ [redacted] សារីន

៤. សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កុសល មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារីន និង ដើមបណ្តឹងរដ្ឋប្បវេណី ។

- បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាសបង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់ដំណែង និង កងកម្លាំងប្រដាប់*



Scanned with CamScanner

រាជធានីភ្នំពេញ ... ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ហើយ ។

**ក្រឡាបញ្ជី**
ហត្ថលេខា : [redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា : [redacted]

**ប្រធានក្រុមប្រឹក្សា**
ហត្ថលេខា : [redacted]

---

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០១៤
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner